## អារម្ភកថា

ឧបនិស្ស័យនៃបុព្វបុរសខ្មែរ ច្រើនកសាងអ្វីៗក្នុងលក្ខណៈល្អឥតខ្ចោះ ។ មានមរតកជាច្រើន ត្រូវបានមតិអន្តរជាតិកោតស្ញប់ស្ញែង ហើយចាត់ជាសម្បត្តិរបស់មនុស្សជាតិ ។ នៅក្នុងសិល្បៈខ្មែរទាំងអស់នោះ មិនមែនមានតែសោភ័ណប៉ុណ្ណោះទេ តែក៏បានបង្ហាញនូវទេពកោសល្យ បញ្ញា សេចក្តីព្យាយាម ការអត់ធ្មត់ និង និមិត្តកម្មផង ។

ម្យ៉ាងទៀត បើយើងសង្កេតពីជីវភាពរស់នៅរបស់ខ្មែរបុរាណ លោកច្រើននិយមប្រើប្រាស់តែវត្ថុធាតុមានតម្លៃ ។ ដូចជាផ្តិល ជើងពាន ខ្សែក្រវាត់ ខ្សែអាវ ខ្សែអាវទ្រនាប់ ប្រដាប់គ្រឿងម្ហូប..... ច្រើនផលិតពីមាស ប្រាក់ សំរិទ្ធិ ឬយ៉ាងទាបបំផុតក៏ប្រើប្រាស់អំពីស្ពាន់ដែរ ។ ចំពោះសម្លៀកបំពាក់ច្រើនផលិតពីសូត្រ ដែលមានច្រើនបែប សំរាប់ស្លៀកនៅពេលផ្សេងៗគ្នា ។

ឧបនិស្ស័យដ៏ខ្ពង់ខ្ពស់របស់លោកនេះ ក្រោយពេលរបបប្រល័យពូជសាសន៍ដួលរលំ ហាក់កប់បាត់ច្រើនតាមព្រលឹងអ្នកចែកឋានទៅដែរ ។ ហេតុអស់នេះហើយ ដែលបានធ្វើឱ្យយើងខ្ញុំខិតខំប្រមូលឯកសារ ចងក្រងជាកូនសៀវភៅនេះ គ្រាន់បានអ្នកបន្តវេនជំនាន់ក្រោយនឹកឃើញឡើងវិញពីកេរដំណែលរបស់ដូនតាខ្លួន ដែលប្រកបទៅដោយឧបនិស្ស័យខ្ពង់ខ្ពស់ក្នុងការច្នៃប្រឌិត ។

ភ្នំពេញ ថ្ងៃ ៦ ខែ មករា ឆ្នាំ ២០០៧

**កែវ ណារុំ**



# របាំបុរាណខ្មែរ

***បុព្វ***បុរសខ្មែរបានបង្កើតរបាំបុរាណ មានភាពល្អឥតខ្ចោះ មានឈ្មោះល្បីលើឆាកអន្តរជាតិ ។ គេប្រៀបប្រដូចថាជាទេវតាបង្កើត ។ អ្នកប្រាជ្ញផ្នែកខាងសិល្បៈបានចាត់ជាបេតិកភ័ណ្ឌវប្បធម៌អរូបីយ៍ សម្បត្តិរបស់មនុស្សជាតិ នៅថ្ងៃទី៣ខែវិច្ឆិកា ឆ្នាំ ២០០៣ ។

របាំបុរាណនេះជាសិល្បៈទីបញ្ចប់ ឥតកែប្រែឡើយ គឺជាសិល្បៈពិសិដ្ឋ។ ការតាក់តែងកាយច្រើនបង្ហាញពីភាពខ្ពង់ខ្ពស់ ដែលប្រកបទៅដោយសំលៀកបំពាក់ភ្លឺចិញ្ចាចចិញ្ចែង មានរស្មីដូចព្រះអាទិត្យឬព្រះច័ន្ទ សំរាប់ពពួកទេវតាឬពពួកអ្នកស្ថានសួគ៌ ។ ម្យ៉ាងទៀតសិល្បៈនេះមានលក្ខណៈហួសពីសោភ័ណវិទ្យា បានផ្តល់ឱ្យទស្សនិកជនរំភើបអណ្តែតត្រសែតទៅរកពិភពនៃក្តីស្ងប់និងត្រជាក់ពេញចិត្ត ។ អ្នកប្រាជ្ញខាងសិល្បៈក៏បានទទួលស្គាល់ទៀតថា ជាសិល្បៈពិសេសខាងកាយវិការដែលមានលក្ខណៈប្លែក តែជាសកល។ ទោះបីជាមានកាយវិការខ្លះ មានការលំបាកយល់ចំពោះជនសាមញ្ញ តែក៏បានផ្តល់ឱ្យគេជក់អារម្មណ៍ពីសម្ផស្សនៃរូបារម្មណ៍ដែរ ។ ក្បាច់ទន់ភ្លន់អែនអន បានបញ្ឆោតក្តុអ្នកទស្សនាឱ្យកើតនូវក្តីស្រមៃ ឬកំពុងឋិតក្នុងពិភពសួគ៌ា ហើយផ្តិតយកនូវរូបភាពមួយចំនួន ដែលបង្កឱ្យគេកើតក្តីសុខដុម ។ ឯការរៀបចំឆាកច្រើនមានលក្ខណៈជានិមិត្តរូប ដូចជាការលំអដោយមានដាក់ដើមឈើបញ្ឈរ គេតែងប្រើពណ៌ទឹកមាសឬទឹកប្រាក់ ដែលគេហៅថាដើមមាសដើមប្រាក់ ហើយបើមានផ្លែផ្កានោះ ក៏ជាមាសឬប្រាក់ដែរ ។

ចំពោះតួដែលត្រូវសំដែងក្នុងលក្ខណៈជាសត្វក៏ដោយ ក៏សត្វនោះច្រើនថិតក្នុងលក្ខណៈខ្ពង់ខ្ពស់ទៀតដែរ ។

របាំបុរាណខ្មែរ គឺជាសិល្បៈគំនិតដែលប្រើនិមិត្តរូបនិយម ។ ការបង្កើតក្បាច់គឺចេញពីមូលដ្ឋានជីវិតនិងធម្មជាតិ ។ ក្បាច់ទាំងនេះយើងមើលទៅឃើញថា មានលក្ខណៈយឺត ហើយហាក់ដូចជាទន់ជ្រាយ តែធាតុពិតគឺទន់ភ្លន់ ។ គ្រប់សរសៃទាំងអស់ សុទ្ធតែផ្ទុកទៅដោយការប្រឹង គឺអ្នករាំសុទ្ធតែបានប្រើកំលាំងគ្រប់ដង្ហើម ។ ដូចជាម្រាមមេដៃនិងម្រាមចង្អុលដៃជីបជាប់គ្នា ដែលយើងអាចហៅថា ត្រួយឬផ្កាក្រពុំនោះ ពេលយកក្បាច់នេះមកដាក់ចុងដង្ហើម មានន័យថា«ខ្ញុំ» ។ ដើម្បីឱ្យបានន័យថា **ខ្ញុំ** មួយម៉ាត់ មុននឹងសំរេចបានគេត្រូវប្រើកំលាំងនិងដង្ហើមចង្វាក់ (Rythme) ៥ ។ ដំបូងត្រូវលើកដៃ ហើយលាបាតដៃ រួចផ្ទារជីប រួចបានលើកយកមកដាក់លើទ្រូងចុងដង្ហើម....។ **ខ្ញុំ**នេះ គឺប្រៀបដូចផ្កា ។ ធម្មតាភាគច្រើននៃផ្កាគឺល្អទាំងរូប ល្អទាំងក្លិន ។ ដូច្នេះ ខ្លួនខ្ញុំដែលប្រដូចទៅនឹងផ្កា ព្រោះយល់ថាខ្លួនឯងល្អ គឺល្អទាំងរូប ល្អទាំងកេរ្តិ៍ឈ្មោះ ល្អទាំងចិត្ត គឺជាលំអនៃគ្រួសារនិងសង្គម ។ បីដូចជាផ្កាលំអសំរាប់ធម្មជាតិ ហើយដែលនឹងរោយទៅវិញនៅថ្ងៃណាមួយមិនខាន ។

កាយវិការចង្អុលឬការដុះពន្លក សំរាប់បង្ហាញប្រាប់ពីន័យដែលត្រូវអធិប្បាយ ។ បើគេនិយាយពីអ្វីៗដែលថិតនៅជិត គេចង្អុលទៅខាងមុខបន្តិច ។ តែបើចង់និយាយពីអ្វីដែលនៅឆ្ងាយ គេត្រូវលើកដៃចង្អុលទៅមុខបន្តិចទៀត ។ ឯចំពោះអ្នកដែលតូចជាង ដូចជាប្អូន កូនចៅជាដើម គេយកក្បាច់នេះចង្អុលទៅខាងចំហៀងខ្លួន ។ តែបើនិយាយចំពោះអ្នកដែលធំជាង មានមាតាបិតាជាដើម គេលើកក្បាច់នេះស្ទួយខ្ពស់ទៅលើ ។



កាយវិការពត់កដៃ ដោយប្រើម្រាមដៃ៤-ង មានសភាពដូចស្លឹក ។ គេយកស្លឹកមកបាំងថ្ពាល់ នៅពេលអៀនខ្មាស់ ។ តែបើយកស្លឹកមកបាំងនៅខាងលើភ្នែក មានន័យថា យំ ។ មនុស្សដែលយំមិនចង់ឱ្យអ្នកដទៃមើលឃើញទេ ព្រោះការយំឬមានទុក្ខ មុខមិនដែលល្អឡើយ ។ ដូចនេះគេត្រូវតែបាំងជិតមិនឱ្យនរណាឃើញ ។

ម្រាមចង្អុលឬម្រាមកណ្តាលប្រឹង-ងស្មើត ឯម្រាមបីទៀតឱនត្លបគ្នា គឺការបែកមែក ។ សំរាប់ប្រើក្នុងន័យផ្សេងៗ ដូចជាប្រើសំរាប់សំគាល់ថាស្នែងសត្វជាដើម ។

ម្រាមដៃទាំងប្រាំជីបគឺជាផ្កា ព្រោះវាមានលក្ខណៈដូចជាផ្កាមែន ។

ម្រាមដៃបួនក្តាប់ ដោយឱ្យម្រាមមេប្រឹងនោះ គឺជាផ្លែឈើក្តឹប ។ សំរាប់ប្រើកាន់ដំបងឬដាវ លំពែង ក្នុងពេលប្រយុទ្ធ....។

ម្រាមកណ្តាលនិងម្រាមមេឱនត្លបគ្នា គឺជាផ្លែចាស់ បន្តិចទៀតនឹងត្រូវទុំជ្រុះ ។

បន្ទាប់មកគេផ្ទាត់លា ឃ្លាតចាកពីគ្នានោះ គឺជាផ្លែទុំជ្រុះ ។ គេច្រើនប្រើក្បាច់នេះនៅពេលរាំជិតបញ្ចប់របាំ ដូចជារបាំទេពមនោរម្យ ។ មានន័យថាលាគ្នា មុននឹងហោះទៅកាន់ថានសួគ៌ ។

ពេលហោះ អ្នករបាំរាំឆ្វែលចុះឆ្វែលឡើង លើកដៃម្ខាងពត់កោងទៅលើនិងម្ខាងទៀតង-កោងត្រង់ក្លួយដៃ ដែលជាការប្រឹងហាត់ពត់ខ្លាំងណាស់ទើបមានលក្ខណៈល្អបណ្តាច់ ។

ចំពោះកាយវិការខឹង ស្រឡាញ់ ស្អប់ តែងបានដកស្រង់យកពីជីវិតមនុស្សយើងគ្រប់ៗគ្នា ។ ដូចជាយកដៃទាំងពីរមកខ្វែងឱបលើទ្រូង នេះគឺជាសញ្ញានៃក្តីស្រឡាញ់ ។ តែបើខឹងគឺលើកដៃចង្អុលឱ្យខ្លាំង ឬបានបន្ថែម

ជើងទន្ទ្រាំទៀតនោះ គឺជាសញ្ញាខឹងខ្លាំងមែនទែន ។

ម៉្យាងទៀតនៅក្នុងរបាំបុរាណនេះ ការហាត់រៀនគេចែកចេញជាបួនក្រុម ចំពោះការជ្រើសរើសគឺយកតាមលក្ខណៈរូបសម្បត្តិពីកំណើត ។ ក្រុមទាំងបួននោះមាន : ក្រុមនាងដំណាងឱ្យស្រីភេទ ក្រុមនាយរោងដំណាងឱ្យភេទបុរស ក្រុមយក្សដំណាងឱ្យពពួកយក្ស ពួកងោះ(មនុស្សដែលមានរូបមិនល្អ) ។ ចំពោះក្រុមពួកស្វា ពីដើមឡើយច្រើនពួកកុមារីរាំ ។ តែមកដល់រាជ្យព្រះករុណានរោត្តមសីហនុ(១៩៤០-៤១) ។ សម្តេចព្រះមាតារបស់ព្រះអង្គ គឺក្រោយមកលោកជាសម្តេចព្រះមហាក្សត្រីយានី ស៊ីសុវត្ថិកុសមៈនារីរត្ន សិរីវឌ្ឍនា លោកគ្រប់គ្រងវិញ ព្រះអង្គបានជ្រើសរើសកុមារារាំវិញ ព្រោះអាចរាំបានចិតថេរជាងរហូត ។

ចំពោះកាយវិការនៃក្រុមទាំងបួនពួកនេះ មិនមានលក្ខណៈដូចគ្នាឡើយ ដូចជាក្បាច់យំ ÷

សំរាប់តួនាង ដែលជាស្ត្រីភេទមានភាពទន់ភ្លន់នោះ គេយកដៃបាំងលើភ្នែក ដោយមិនលើកបើកក្លៀកឡើយ ។

តួនាយរោង គឺជាតួបុរសភេទ ត្រូវមានភាពសង្ហារស្វាហាប់ ទោះបីជាគេយំក៏ដោយ ក៏គេត្រូវរក្សាលក្ខណៈរឹងប៉ឹងដដែល ។ គឺគេយកដៃបាំងមុខដោយកន្ទែកម្រាមមេដៃនិងម្រាមចង្អុលឱ្យទាល់តែតឹង រួចបើកក្លៀកចេញបន្តិច ។

តួស្វាយំ គេមិនប្រើបាតដៃឬសន្ទឹកបាំងមុខទេ គឺគេយកម្រាមមេដៃនិងម្រាមចង្អុលដៃជីបជាប់គ្នា រួចកាច់កដៃក្រងិចុះក្រោម ដោយដាក់បាំងមុខដែរ ។

តួយក្សយំ គេនៅតែតំណាងឱ្យលក្ខណៈកាច ខ្លាំងដដែល គឺគេឈរ






*(រូបភាពដកស្រង់ពីសៀវភៅ "របាំខ្មែរ" របស់អ្នកនិពន្ធ ពេជ្រទុំក្រវិល)*

កន្ទែកជើង ដោយឱនក្បាលបន្តិច រួចក្តាប់ដៃហើយយកកំភួនដៃបាំងមុខដែរ ។

របាំបុរាណមានលក្ខណៈល្អពិសេសមួយទៀត ត្រង់ប្រើដងខ្លួនឱ្យចិតក្នុងលំនឹង (Equilibre)គឺមិនផ្អៀង មិនភ្លូក ឬ កាច់ចង្កេះក្រវិក្រវក់ចុះឡើងឡើយ ។ គេតែងរំកិលខ្លួនដូចអណ្តែតលើអាកាស ហើយត្រូវហាត់ចេះទប់ខ្លួនឱ្យមានលំនឹងកុំឱ្យរង្គើ ។ ដងខ្លួននោះត្រូវទន់ភ្លន់អែនអនដូចពស់វារ ។ បញ្ហានេះ ក៏ជាលក្ខណៈពិសេសដែលជនសាមញ្ញពិបាកធ្វើបាន ។

# អប្សរា

**ពាក្យ**អប្សរា(សំ.) មានន័យដូចគ្នានឹងពាក្យអច្ឆរា(បា.) គឺជាស្រីសួគ៌ មានសម្បុរស្រស់ថ្លាផូរផង់ ។ ចំពោះសេចក្តីតំណាលក្នុងគម្ពីរព្រាហ្មណ៍ថា នាងជាស្រីសួគ៌មួយពួកកើតចេញពីការកូរសមុទ្រទឹកដោះ ដើម្បីចម្រាញ់យកទឹកអម្រឹត ។ បានសេចក្តីថា ក្នុងការកូរមានការលេចចេញនូវសត្វចម្លែកអស្ចារ្យជាច្រើនជាបន្តបន្ទាប់ ដូចជា : ដំរីឰរាវ័នដែលព្រះឥន្ទ្រយកទៅធ្វើជាជំនិះ ។ បន្ទាប់មកនាងអប្សរាដែលពត់ពេនរាំនៅលើនភាល័យ នាងទេពធីតាស្រីុដំណាងឱ្យស្រ្តីភេទនិងជាទេវៈនៃសោភ័ណ នាងលក្សីជាទេវៈតំណាងឱ្យទ្រព្យសម្បត្តិ ផ្កាតំណាងឱ្យធម្មជាតិ,...។ នៅទីបញ្ចប់ គឺទឹកអម្រឹតដែលជាកម្មវត្ថុនឹងបានផឹក ដើម្បីឱ្យមានជីវិតជាអមតៈ។

រឿង **«កូរសមុទ្រទឹកដោះ»** គឺជារឿងទេវកថា ដែលប្រជារាស្រ្តខ្មែរសម័យបុរាណនិយម ពិសេសសម័យអង្គរ ដែលអាចចូលចិត្តជក់អារម្មណ៍។ តឹកតាង យើងបានឃើញបុព្វបុរសខ្មែរបានបន្សល់ទុកនូវចម្លាក់ដ៏ល្អប្រណីតជាច្រើននៅតាមប្រាសាទនានា ដែលទាក់ទងនឹងប្រធានបទនេះ ។ ក្នុងនេះមានរូបចម្លាក់ដ៏ល្អវិសេសមួយ គឺនៅប្រាសាទអង្គរវត្តថែវខាងកើត មានបណ្តោយប្រវែង៤៩ម៉ែត្រនិងកំពស់២ម៉ែត្រ ។ ក្នុងនោះគេឃើញមាននាងអប្សរាដ៏ច្រើន កំពុងរេរាំនៅផ្នែកខាងលើ ។ ម្យ៉ាងទៀត យើងក៏តែងមានការចាប់អារម្មណ៍យ៉ាងខ្លាំងដែរ ពីចម្លាក់រូបនាងអប្សរារាប់ពាន់ដែលបានឆ្លាក់នៅប្រាសាទអង្គរវត្ត សម្តែងនូវកាយវិការប្លែកខុសៗគ្នាទាំងអស់ ។ ចំណែកនៅប្រាសាទដទៃទៀតនោះ ថ្វីត្បិតតែមិនមានឆ្លាក់នាងអប្សរាដ៏ច្រើន





*ចំលាក់រឿង "កូរសមុទ្រទឹកដោះ" នៅជញ្ជាំងប្រាសាទអង្គរវត្ត ខាងកើតជៀងខាងត្បូង*

ដូចនៅប្រាសាទអង្គរវត្តមែនពិត តែគេក៏មិនបានភ្លេចឆ្លាក់ពួកនាងដែរ ។

នាងអប្សរា គឺជានាងទេពធីតាឬទេវតាស្រី ដំណាងឱ្យក្តីស្វាគមន៍និងជូនពរនូវសុភមង្គល សិរីសួស្តី...។ តាមទំនៀមទំលាប់ប្រពៃណីខ្មែរ បានប្រកាន់យករបបមាតាធិបតេយ្យ ហើយតែងមានជំនឿថា ស្រីជាអ្នកនាំមកសិរីមង្គលឬអព្ភមង្គល ។ ប៉ុន្តែនាងអប្សរា សុទ្ធតែជាស្រ្តីបរិសុទ្ធ នាងជាអ្នកតំណាងសុំក្តីប្រោសប្រណីពីអទិទេពឬវត្ថុស័ក្តិសិទ្ធិ ហើយពាំនាំពរពីស្ថានសួគ៌មកវិញនូវសេចក្តីសុខ សេចក្តីចំរើនជូនមនុស្សលោក ។

រូបារម្មណ៍អប្សរា គឺដំណាងឱ្យរបាំ ដែលជាមាតានៃសិល្បៈទាំងឡាយ។ លក្ខណៈកំពូលនៃរូបារម្មណ៍នេះ គឺសំដែងចេញឡើងនៅក្នុងក្បាច់របាំ ដែលរៀបរាប់អំពីជីវិតមនុស្សនិងធម្មជាតិ ។ ហេតុដូច្នេះហើយ ទើបយើងឃើញ

នៅពេលរាំ នាងអប្សរាតែងតែកាន់ផ្កាដែលជានិមិត្តរូបនៃធម្មជាតិ។ ចំណែកពេលនាងកាន់ផ្កាហើយបង្វិលចុះឡើងនោះ គឺជានិមិត្តរូបនៃការវិលចុះឡើងនៃវាលវដ្តសង្សារ ។ ម៉្យាងទៀតរូបារម្មណ៍អប្សរា ក៏បានបង្ហាញពីទស្សនៈរបស់សិល្បករនិងប្រជាជនខ្មែរបុរាណ ដែលនិយមការត្រិះរិះនិងភាពពិតប្រាកដប្រជាំ ។ ទោះបីជារស់ក្នុងព្រហ្មញ្ញសាសនាឬពុទ្ធសាសនា នាងអប្សរានៅតែរក្សាតួនាទីយ៉ាងខ្ជាប់ខ្ជួនជានិច្ច ។ តែតាមការសង្កេត យើងឃើញនាងអប្សរានៅតាមប្រាសាទនានា ដែលស្ថាបនាក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ដែលលោកងាកមកកាន់ពុទ្ធសាសនានោះ រូបចម្លាក់នាងអប្សរាតែងកាន់កម្រងផ្កាម្លិះឬផ្កាឈូក ។ ប្រការនេះយើងអាចសន្និដ្ឋានបានថាផ្កាម្លិះជាផ្កាមានក្លិនក្រអូបនិងមានពណ៌ស ជាពណ៌បរិសុទ្ធ បានតំណាងឱ្យផ្កាទាំងឡាយនៅលើលោក ។ ឯផ្កាឈូក ថ្វីត្បិតតែដុះនៅក្នុងភក់មែនពិតក៏តែងនៅរក្សាបានភាពស្អាតបរិសុទ្ធដែរ ហើយក៏បានតំណាងឱ្យផ្កាក្នុងទឹកទាំងអស់ ។ ម៉្យាងទៀតដូចយើងបានឃើញហើយ ព្រះរតនៈបល្ល័ង្ករបស់ព្រះពុទ្ធ គេតែងនិយមធ្វើជារាងផ្កាឈូក ។ ផ្កាឈូកនេះក៏មានរឿងទាក់ទងនឹងព្រះពុទ្ធ ដែលមានសត្វដំរីបានកាច់ផ្កាឈូកថ្វាយព្រះពុទ្ធអង្គ ជាមួយសត្វស្វាថ្វាយឃ្មុំ ។ បច្ចុប្បន្ននេះនៅពេលប្រារព្ធពិធីបុណ្យផ្សេងៗ ជាពិសេសពិធីអភិសេកព្រះពុទ្ធរូប រាស្ត្រខ្មែរតែងបាចផ្កាម្លិះនិងផ្កាឈូកថ្វាយព្រះពុទ្ធក្នុងឱកាសផ្ចាញ់មារ ។ ចំពោះនាងអប្សរានៅប្រាសាទផ្សេងទៀត ដែលកសាងឡើងដោយព្រះមហាក្សត្រមិនកាន់សាសនាព្រះពុទ្ធ យើងសង្កេតឃើញនាងកាន់ផ្កាផ្សេងៗ ដែលបច្ចុប្បន្ននេះយើងហៅថាផ្កាមាសផ្កាប្រាក់។ ផ្កាទាំងអស់ដែលនាងអប្សរាកាន់ តំណាងជាពិសេសមួយទៀត គឺការស្រឡាញ់អំពើយុត្តិធម៌និងសេចក្តីស្មោះត្រង់ ដែលជាអ្នកមានចិត្តគំនិតខ្ពស់



ចំពោះការស្រឡាញ់អំពើល្អ ។ មនុស្សដែលស្រឡាញ់ថ្នាក់ថ្នមផ្កា អាចបង្ហាញឱ្យយើងដឹងខ្លះបានថា ជាមនុស្សមានឧត្តមគតិខ្លះក្នុងការការពារមនុស្សជាតិ ។...

ចំពោះរបាំអប្សរាដែលទើបនឹងកើតមានក្នុងគ្រាដំបូង ត្រូវបានយកលំនាំតាមបែបនាងអប្សរានៅតាមចម្លាក់ប្រាសាទនានា ក្នុងសម័យចក្រភពអង្គរ។ របាំនេះកកើតជារូបរាងនៅសម័យចុងទសវត្សទី១៩៥០ ដោយស្នាព្រះហស្តសម្តេចព្រះរាជកន្និដ្ឋានរោត្តមស្មើសោភ័ណ ជាព្រះអនុជនៃព្រះករុណាព្រះបាទនរោត្តមសុរាម្រឹត ។ រាំជាតួឯកដោយព្រះអង្គម្ចាស់ក្សត្រីនរោត្តមវិជ្ជរា ជាព្រះរាជបុត្រីនៃព្រះបាទនរោត្តមសុរាម្រឹត ។ បន្ទាប់មករាំដោយព្រះអង្គម្ចាស់ក្សត្រីសុជាតិវត្តីយា ជាព្រះរាជបុត្រីនៃព្រះបាទនរោត្តមសីហនុ។ ប៉ុន្តែទោះបីជាស្លៀកពាក់តាមរបៀបចម្លាក់នាងអប្សរា នៅប្រាសាទក៏ដោយនោះ អ្នកស្រី **ឯម ធាយ** ជាព្រឹទ្ធាចារ្យសិល្បៈ ធ្លាប់ជាសិល្បការិនីនៅព្រះបរមរាជវាំង បានមានប្រសាសន៍ថា ពេលនោះមានឈ្មោះថា **«របាំចំប៉ាមាស ឆេស»** ។.....

ឈ្មោះត្រូវបានប្រែមកជា របាំអប្សរា ហើយឈានដល់កំរិតកំពូលល្អឥតខ្ចោះនោះ កើតក្រោមព្រះរាជកិច្ចដឹកនាំដោយម៉ត់ចត់និងឈ្លាសវៃនៃសម្តេចព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា ។ របាំនេះបានចេញរាំជាដំបូងនៅខេត្តសៀមរាបអង្គរ ដើម្បីថតជាខ្សែភាពយន្តដោយលោក ម៉ាកសែល កាមីស ? ក្នុងអំឡុងឆ្នាំ១៩៦១ ឬ ១៩៦២ ?។ បន្ទាប់មកបានចេញទៅរាំនៅប្រទេសបារាំងក្នុងឆ្នាំ១៩៦៣ ហើយរាំនៅសិង្ហបុរីនៅឆ្នាំ១៩៦៤? ក្នុងពិធីសម្ពោធមហោស្រពសិល្បៈទូទាំងសកល។ ពេលនោះរបាំអប្សរាបានទទួលជោគជ័យ មានឈ្មោះល្បីល្បាញ ទទួលការគោត

សរសើរពីអ្នកទស្សនាយ៉ាងខ្លាំង។ ខណៈនោះហើយ ដែលធ្វើឱ្យមតិវិនិច្ឆ័យនៃពិភពលោក បានរកឃើញនូវសច្ចភាពគ្មានស្រពេចស្រពិល ចំពោះតំលៃនៃទេពកោសល្យរបស់ប្រជារាស្ត្រខ្មែរ។ យើងត្រូវទទួលស្គាល់ដែរថា ជោគជ័យនេះទទួលបាន ក៏ដោយសារព្រះទេពកោសល្យដ៏អស្ចារ្យនៃព្រះអង្គម្ចាស់ក្សត្រីនរោត្តមបុប្ផាទេវី ដែលជាតួឯកដំបូងនៃរបាំនេះ ។



# សិល្បៈស្បែកធំ

***សិល្បៈ***ស្បែកធំ បានចាត់ចូលជាបេតិកភ័ណ្ឌវប្បធម៌អរូបីយ៍នៃសម្បត្តិមនុស្សជាតិ នាថ្ងៃទី២២ខែវិច្ឆិកាឆ្នាំ២០០៥ ។ គេអាចហៅសិល្បៈស្បែកធំនេះថាជាប្រភេទល្ខោនស្រមោល ដែលកើតមាននៅក្នុងប្រទេសជាច្រើនដូចជាប្រទេស : ឥណ្ឌូណេស៊ី ថៃ ឡាវ ឥណ្ឌា អ៊ីរ៉ង់ ទួរគីជាដើម ។ ប៉ុន្តែតន្ត្រីកំដរជូនសិល្បៈនេះ ព្រមទាំងរូបចម្លាក់រាងរៅនៃការសំដែង មានលក្ខណៈខុសៗគ្នា ទៅតាមប្រពៃណីទំនៀមទំលាប់នៃប្រទេសនិមួយៗ។

តាមការសន្និដ្ឋានរបស់អ្នកស្រាវជ្រាវបានយល់ឃើញថា សិល្បៈស្បែកធំ ស្បែកតូចនេះ ជាមាតាបង្កើតសិល្បៈភាពយន្ត ដែលចាប់យកស្រមោលក្នុងការសំដែង ។

ខ្មែរបុរាណយល់ថា ការទៅមើលការសំដែងសិល្បៈស្បែកធំ គឺជាការទៅស្តាប់ធម៌ទេសនា ព្រោះគេច្រើនសំដែងរឿងជាតក ដែលជារឿងរបស់ព្រះសក្យមុនីសព្វញ្ញុពុទ្ធ ដែលលោកបានលុះញ្ញាណពិសេសសំរាប់ដឹងជាតិមុនៗ អាចសំដែងប្រាប់មនុស្សលោក ឱ្យយល់ច្បាស់ពីអំពើដែលជាកុសលនិងអកុសល ។ ម៉្យាងទៀតស្បែកធំ ក៏បាននិទានរឿងពីមហិទ្ធិឫទ្ធិនៃមហាបុរសជាទីស្រឡាញ់របស់ខ្លួនដែរ ។ រឿងទាំងអស់នោះ តែងអប់រំឱ្យយល់ពីភាពតស៊ូរវាងអំពើល្អនិងអំពើអាក្រក់ ។ តែទីបំផុត អំពើល្អតែងទទួលជ័យជំនះ ។ សិល្បៈស្បែកធំក៏តែងបានសំដែងរឿងរាមកេរ្តិ៍នោះ ក៏បានបង្ហាញឱ្យឃើញពីតួអង្គតំណាងឱ្យអំពើល្អមាន ÷ ព្រះរាម ព្រះលក្សណ៍ ហនុ

មាន នាងសិតា....។ ឯពួកអាក្រក់មានក្រុងរាពណ៍និងបក្សពួក ។ ការសំដែងរឿងរាមកេរ្តិ៍នេះ បានធ្វើឱ្យខ្មែរពីដើមចេះចាំយ៉ាងស្ទាត់ ហើយចាត់ទុកសិល្បៈស្បែកធំនេះ ជាសិល្បៈសក្ការៈ ។

នៅពេលសំដែង អ្នកពោលជាមនុស្សសំខាន់ដែលមាននាទីដឹកនាំឬជាគ្រូ ។ លោកគ្រូតែងកាត់កងឱ្យលេងខ្លីឬលេងវែង តាមការប៉ិនប្រសប់រៀបរាប់កំណាព្យកាព្យឃ្លោងពិរោះរណ្តំ ។ អ្នកពោលតែងមានពីរនាក់ ប្រើសំដីឆ្លងឆ្លើយតាមឈុតឈ្មោះប្រកែក ឬកំសត់ស្រណោះ ។ ផ្ទុយទៅវិញមានការសើចសប្បាយតាមការចូលតួសណ្ឋិតនៃសាច់រឿង ។ ចំពោះភ្លេងកំដរសិល្បៈនេះ គឺវង់ភ្លេងពិណពាទ្យ ។ ពេលពោលចប់ម្តងៗ ស្គរធំនិងសម្ភោរទទួលបញ្ចប់ ហើយវាយស្គរធំពីរអន្លូងជាសញ្ញា ។

**របៀបធ្វើស្បែកធំ :**

ការធ្វើស្បែកធំ ដើម្បីបានយកមកសំដែងសិល្បៈនោះ គឺជាមរតកបន្តតាមរបៀបបង្រៀនធ្វើដោយផ្ទាល់ឬច្នៃបន្តិចបន្តួចទៅតាមពេលវេលា ។

ជាដំបូង គេយកស្បែកស្រស់ដែលព្រលាត់ពីគោមកធ្វើភ្នាម ឬក៏ខ្ចប់ផេះទុកមួយរយៈ ការពារកុំឱ្យស្អុយនៅពេលគ្មានថ្ងៃហាល ។ ពេលធ្វើទើបគេរលាស់ផេះចេញ ហើយត្រដាងកោសសាច់វៀរ សរសៃចេញឱ្យស្អាត ។ បន្ទាប់មកគេយកទៅត្រាំទឹកសំបកឈើ ក្នុងរយៈពេលមួយយប់មួយថ្ងៃ ។ សំបកឈើអស់ទាំងនោះ សុទ្ធតែមានរសល្វីងខ្លាំងនិងចត់ខ្លាំង គឺដើម្បីការពារសត្វល្អិតចោះស៊ី ។ ជាបន្តគេស្រង់យកទៅហាលថ្ងៃ ដោយលាតសន្ធឹងលើផ្ទៃដីរាបស្មើ ហើយបោះស្នឹងទាញបន្តឹងយ៉ាងម៉ត់ចត់ ។ ក្រោយពេលស្ងួត គេយកមកកោសរោមបន្ថើរៗឱ្យស្មើសាច់ ព្រោះកន្លែងខ្លះស្តើងកន្លែងខ្លះក្រាស់ ។ ពេលឃើញថាសាច់ស្បែកស្អាតហើយ វិចិត្រករគូររូប





ស្បែកធំ (ដកស្រង់ចេញពីសៀវភៅ ទស្សនីយភាពខ្មែរ ទំព័រ ៧១)

តួអង្គតាមសាច់រឿង ដោយតុបតែងលំអក្បឹផ្សេងៗ ។ បន្ទាប់មកគេដាប់ទំលុះចេញ ដោយបញ្ចាំងធ្លុះពន្លឺភ្លើងឬរស្មីព្រះអាទិត្យ ។ ចុងបញ្ចប់ គេកៀបស្បែកនឹងឫស្សីដូចដំបុកត្រី ។ តែស្បែកដែលធំ គេកៀបពីរដំបុកទន្ទឹមគ្នា បណ្តូរតាមកំពស់ស្បែក ។

# បេតិកភ័ណ្ឌវប្បធម៌រូបីយ៍

**មាន**ប្រាសាទជាច្រើនដែលថិតនៅក្នុងតំបន់អង្គរ ត្រូវបានពិភពលោកចាត់ចូលជាបេតិកភ័ណ្ឌវប្បធម៌រូបីយ៍របស់មនុស្សជាតិ នាឆ្នាំ១៩៩២។ ក្នុងនោះមានប្រាសាទបាយ័ននិងប្រាសាទអង្គរវត្ត ដែលបានធ្វើឱ្យអ្នកទស្សនាចាប់អារម្មណ៍ខ្លាំងជាងគេ ព្រោះស្នាដៃនេះមានលក្ខណៈពិសេសដូចជា ÷

**<u>ប្រាសាទបាយ័ន</u>** :

ក្រៅពីបង្ហាញប្រាប់ពីទេពកោសល្យដ៏អស្ចារ្យ នៃស្ថាបត្យកម្មនិងសិល្បៈចម្លាក់នោះ បាយ័នបានបង្ហាញប្រាប់ពីជីវភាពរស់នៅសម័យចុងសតវត្សទី១២ នៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ។ ចម្លាក់នេះមានលក្ខណៈប្រៀបដូចជាសៀវភៅមួយក្បាលដ៏ធំ បានចារគ្រប់ទំព័រប្លែកៗដូចជា ÷

-បែបបទនៃការរស់នៅ ពីឋានានុក្រមនៃសង្គមខ្មែរ

-វិស័យកសិកម្ម : ប្រឡាយទឹក បន្លែ ដំណាំ

-វិស័យសុខាភិបាល : ការបង្កើតកូនដោយមានឆ្មប,,,

-វិស័យកីឡា : ចំបាប់ ជល់មាន់ ជល់ឆ្កែ ជល់ជ្រូក,,,

-វិស័យសិក្សា : ការបង្ហាត់បង្រៀននៃពួកចារគូ បុរោហិត ដែលជាពួកគ្រូនៃសម័យបុរាណ

-វិស័យសិល្បៈ : តន្ត្រី របាំ សៀក,,,

-វិស័យនេសាទ : ការនេសាទដោយមានឧបករណ៍មងជាដើមនិងជំនួញផ្លូវ...



-វិស័យការពារជាតិ : មានកងទ័ពថ្មើរជើង កងទ័ពដំរី កងទ័ពសេះ កងទ័ពជើងទឹក(ពិសេសចំបាំងជាមួយចាម មានកងទ័ពចិនជួយច្បាំងដែរ )។ រូបភាពច្បាំងមានទូកចំបាំង ដោយមានអ្នកច្បាំងនិងអ្នកអុំ,,។

-ជីវភាពរស់នៅ : ការងារសាងសង់ សិប្បកម្ម ការអាំងសាច់ ឪពុកបញ្ជិះកូនលើស្មា ការដាំស្ល(មនុស្សចំតិតផ្លុំភ្លើង) លេងអុកចត្រង្គ ក្មេងស្រីម្នាក់លួចផ្លែឈើពីអ្នកលក់ ដែលកំពុងដេកលក់,,,។ល។



*មេទ័ពខ្មែរចេញទៅច្បាំង ចំលាក់ប្រាសាទបាយ័ន*

ថែវខាងក្រៅនិយាយពីរឿងរ៉ាវនិងប្រវត្តិសាស្ត្រ ។ ឯផ្នែកខាងក្នុងនិយាយពីអទិទេព ទេវកថា ទស្សនៈចំបងនៃជំនឿទៅលើពុទ្ធស្តេច ។ ចម្លាក់នៅថែវខាងក្នុង ភាគច្រើនជារឿងរបស់ពួកព្រាហ្មណ៍ តាបស និង

ភពចម្លែកៗនៅលាយឡំគ្នា ។ ចម្លាក់ទេពអប្សរមានតិចជាងនៅអង្គរវត្ត តែសិល្បករបានឆ្លាក់មានភាពល្អប្រសើរ ដោយមានកាយវិការរស់រវើក ច្រើនហ៊ុំព័ទ្ធដោយកម្រងស្លឹកឈើ និងពាក់គ្រឿងអលង្ការដ៏ស្កុកស្គម្ភនិងសម្បូរបែប ។ រូបនោះល្អស្រស់ បានបង្ហាញពីភាពផ្អែមល្ហែម ស្រស់ស្អាតក្នុងយុវវ័យ ។

ចម្លាក់នៅប្រាសាទបាយ័ន មានលក្ខណៈជាប្រជារាស្ត្រក្នុងទស្សនៈលោកីយ៍ ។ លើផ្ទាំងចម្លាក់ទាំងអស់នេះ បានបង្ហាញពីភាពល្អឆើត ទាក់



*ទិដ្ឋភាពចំអិនម្ហូប*

*ពីឆ្វេងទៅស្តាំមាន : ការជញ្ជូនម្ហូប(លើ) ការដណ្តាំចាយដោយចាក់អង្ករចូលផ្ទាំង មនុស្សផ្លុំភ្លើង ការធ្វើជ្រូក តំបុតត្រីអាំង*

ទាញចិត្តពីចំនួនបរិមាណដ៏ច្រើនរាប់ម៉ឺន ដែលជាការងារដ៏ធំធេងនិងប្លែកៗ អស្ចារ្យមាន : មនុស្ស សត្វ រុក្ខជាតិ សំភារៈ...។ មានព្រះរាជសវនាការ



ក្នុងព្រះរាជវាំង ផ្ទះមន្ត្រីឬអ្នកមាន ផ្ទះអ្នកស្រុក វត្ត សាលាសំណាក់ស្ពាន ថ្នល់... ។

ប្រាសាទបាយ័នជាប្រាសាទមួយដ៏ធំ បង្ហាញដោយប្រាង្គបីទន្ទឹមគ្នាប្រៀបដូចតួប្រាង្គនៅអង្គរវត្ត (មើលចំពីមុខ) ។ នៅចុងកំពូលនៃប្រាង្គនិមួយៗមានលំអដោយត្រីស្ងូល៍ ។ ការមើលប្រាសាទនេះ បានធ្វើចិត្តអ្នកទស្សនាឱ្យសប្បាយស្ងប់ដោយសាររូបព្រហ្មធ្មេចភ្នែក តែបបូរមាត់ញញឹម។



*ទិដ្ឋភាពសំរាលកូនដោយមានឆ្មប*

## ប្រាសាទអង្គរវត្ត :

សាងដោយព្រះបាទសុរិយាវរ្ម័នទី២ (១១១២-១១៥២) ។ អង្គរវត្តគេកោតស្ញប់ស្ញែងខ្លាំងដោយស្ថាបត្យកម្ម មានបណ្តោយ១៥០០ម. ទទឹង ១៣០០ម. ។ អង្គរវត្តបញ្ជាក់ពីលក្ខណៈអភិជននិងឧត្តមភាពចំណានហើយ

ទាញចិត្តទៅលើរឿងទេវកថាដ៏អស្ចារ្យ ។ ការដើរមើលប្រាសាទនេះ ត្រូវមើលពីឆ្វេងទៅស្តាំ ។ ម៉្យាងទៀតគេត្រូវមើលពេលព្រឹកនិងពេលល្ងាច ព្រោះមើលពេលថ្ងៃ ដុំថ្មអាចចាំងស្រវាំងភ្នែក ។ វេលាព្រះអាទិត្យទៀបអស្តង្គត ពន្លឺក្រហមប្រាលឆ្អៅចោលមកលើប្រាសាទ ងើបមើលទៅលើពពករសាត់លឿនលយ ដោយហោជាងមានក្បាច់រស់រវើក ។ អ្នកមើលគោតស្ញប់ស្ញែងព្រឺខ្លួន អណ្តែតអណ្តូង,... ។ ពេលមើលពីចម្ងាយ យើងឃើញប្រាសាទនេះតូចច្រឡឹង តែបើចូលទៅកាន់តែជិតឡើងៗនោះ ប្រែជាមានភាពសំបើមអស្ចារ្យ ។ នេះក៏ដោយសារទំហំនិងកំពស់មានលក្ខណៈ



*ប្រាសាទអង្គរវត្ត មើលពីជ្រុងលិចឆៀងខាងត្បូង*

តម្រូវគ្នាទៅវិញទៅមក ធ្វើឱ្យប្រាសាទមិនមានរាងកន្ទៀបឬស្រឡះពេក ។



អ្នកដែលទៅមើលជាលើកដំបូង តែងកើតចិត្តរំភើបខ្លាំង ដោយក្តីស្ញប់ស្ញែងនិងស្ងើចសរសើរ ។



*ប្រាសាទអង្គរវត្ត មើលចំពីខាងជើងឆៀងខាងលិច*

ប្រាសាទអង្គរវត្តស្ថិតនៅខាងត្បូងប្រាសាទនគរធំចំងាយ១៥០០ម, បែរមុខទៅទិសខាងលិច ហើយផ្លូវចូលក៏នៅខាងលិចដែរ ដែលខុសនឹងច្បាប់នៃការសាងប្រាសាទ ។ លោក ហង្ស៊ី ម៉ាសាល់ សរសេរថា : ព្រោះមកពីស្ទឹងនៅខាងកើត ហើយប្រាសាទនេះស្ថិតនៅចំផ្លូវទៅកាន់អង្គរធំផង ។ បើតាមទំនៀមខ្មែរថា : ការកប់សពឬតំកល់សពសំរាប់ធ្វើឈាបនកិច្ច គេតែងដាក់ក្បាលបែរទៅទិសខាងលិច ហើយបែរមុខមកខាងកើត ។ ដូច្នេះប្រាសាទអង្គរវត្តដែលត្រូវឧទ្ទិសថ្វាយព្រះបរមពិស្ណុលោក ក៏ត្រូវបែរមុខទៅទិសខាងលិចដែរ ។ ព្រោះគេឧទ្ទិសថ្វាយព្រះបាទសុរិយាវរ្ម័នទី២ «បរមពិស្ណុលោក» ដែលទ្រង់ទិវង្គតទៅនោះ ដូចជាព្រះអាទិត្យរះឡើង ហើយលិចបាត់ទៅទិសខាងលិចដូច្នោះដែរ ។

ប្រាសាទអង្គរវត្តមានបីជាន់ នៅគ្រប់ជ្រុងអនុទិសសុទ្ធតែមានកំពូល

ខ្ពស់ស្រួចជាត្តប្រាង្គ មានជណ្តើរប្រកបដោយសីហៈ ។ នៅជាន់ទី៣ខាងលើ តេហៅថា«បាកាន» មានកំពូលស្រួចទៅកាន់អាកាស មើលពីចម្ងាយឃើញខ្ពស់ស្កឹមស្កៃដូចភ្នំព្រះសុមេរុ ឃើញតែកំពូលច្រូងច្រាងដូចជាវិមានអណ្តែត ។ ប្រាសាទនេះមានឈ្មោះល្បីរន្ទឺ ក៏ដោយសារស្ថាបត្យកម្ម។ អ្នករៀបចំគំរោងនេះ ពិតជាចេះធរណីមាត្រសាស្ត្រក្នុងលំហច្បាស់លាស់ ហើយជាមនុស្សវិសេសវិសាលកម្រមាន ។ ភាពល្អប្រណីតនេះ បានធ្វើឱ្យអ្នកប្រាជ្ញខាងស្ថាបត្យកម្មខ្លះ បានប្រៀបប្រដូចអង្គរវត្តទៅនឹងសម្លេងភ្លេងពិរោះមួយវង់ ដែលប្រគុំដោយផ្ទាំងសិលាជាច្រើន ។



# ប្រាសាទព្រះវិហារ

**ប្រាសាទ**ព្រះវិហារជាប្រាសាទភ្នំ សង់លាតសន្ធឹងលើជួរភ្នំដងរែក ដែលមានជីរាប ។ មានកំពស់ជាង៦០០ម៉ែត្រ ។ (តាមផែនទីភូមិសាស្ត្របារាំងថា មានកំពស់ជាង៦២៥ម៉ែត្រ ឯតាមភូមិសាស្ត្រអង់គ្លេសថា មានកំពស់៦១៦ម៉ែត្រ ។ ផែនទីទាំងពីរនោះសុទ្ធតែពោលជាម៉ែត្រទាំងអស់) ប្រាសាទនេះឋិតនៅក្នុងខេត្តព្រះវិហារ ជាប់ទល់ដែនថៃ ។ គេដាក់នាមថាខេត្តព្រះវិហារគឺយោលតាមឈ្មោះនៃប្រាសាទនេះ ដែលបានបំបែកចេញពីខេត្តកំពង់ធំ ។ ប្រាសាទព្រះវិហារសង់បែរមុខទៅទិសខាងជើង ។ ខ្លង់រាបពីទិសខាងជើងទៅខាងត្បូង មានប្រវែងប្រមាណជាង៩០០ម៉ែត្រ។ ចំណែកប្រាសាទដែលសង់នៅត្រង់តែមខាងត្បូងបំផុត បានពន្លូតទៅទិសខាងជើង ដោយមានថ្នល់មួយទៅទល់នឹងចុងបំផុតនៃខ្លង់រាប ។ នៅត្រង់ជើងនៃតួប្រាសាទខាងត្បូងមានសភាពចោតមកលើដីវាលកម្ពុជា ។ ចំណែកឯត្រង់ទិសខាងជើង នៅទីបំផុតនៃខ្លង់រាប ដីមានភាពទេរជំរាលទៅរកប្រទេសថៃ ។ បញ្ហានេះហើយដែលនាំឱ្យអ្នកកសាងប្រាសាទ ពន្លូតថ្នល់ជណ្តើរពីខាងជើងទៅខាងត្បូង ។ ខ្លង់រាបនេះរាប់ចូលក្នុងជួរភ្នំនៅត្រង់បន្ទាត់បែងចែក ។ ប៉ុន្តែសង់តាមគោលដែលទាក់ទងនឹងទឹកដីខ្មែរទាំងស្រុងនៅសម័យចក្រភពអង្គរ ។ មានឯកសារជាច្រើននិយាយពីប្រាសាទព្រះវិហារ។ ប៉ុន្តែក៏មានរៀបរាប់ពីស្តេចខុសៗគ្នាខ្លះដែរ ។ មិនតែប៉ុណ្ណោះឆ្នាំសោយរាជ្យក៏មានកាលខុសៗគ្នាទៀត ។



ប្រាសាទព្រះវិហារ ស្ថិតក្នុងខេត្តព្រះវិហារ

ប្រាសាទព្រះវិហារកសាងឡើងដោយបុព្វបុរសខ្មែរ ក្នុងរាជ្យស្តេចច្រើនអង្គបន្តបន្ទាប់ :

១-ព្រះបាទយសោវរ្ម័នទី១ គ.ស ៨៨៩-៩១០ (៩០០?)



២-ព្រះបាទរាជេន្ទ្រវរ្ម័នទី២(ជ័យវរ្ម័នទី៥?)គ.ស ៩៤៤-១០០១

៣-ព្រះបាទសុរិយាវរ្ម័នទី១ គ.ស ១០១២-១០៥០ (១០០២?)

៤-ព្រះបាទឧទ្យាទិត្យវរ្ម័នទី២ គ.ស ១០៤៩-១០៦៦ (១០៥០?)

៥-ព្រះបាទជ័យវរ្ម័នទី៦(ហស៌វរ្ម័នទី៣?) គ.ស ១០៨០-១០៩០

៦-ព្រះបាទសុរិយាវរ្ម័នទី២ គ.ស ១១១២-១១៥២ (១១១៣-១១៦២?)

ក្នុងរាជ្យស្តេចនិមួយៗ តែងមានការរៀបចំសាងសង់ថ្មីៗជាបន្តបន្ទាប់ ដែលគេសង្កេតឃើញនោះ ច្បាស់ជាមានកាលបរិច្ឆេទនៅសម័យនៃការសាងសង់ផ្សេងៗមិនខាន ។ ការកសាងនេះគឺដើម្បីដឹងគុណដល់ព្រះស្រីសិខរស្វរៈ គឺព្រះសិវៈជាអម្ចាស់ដ៏ឧត្តមបំផុតនោះ ប្រកបដោយលក្ខណៈល្អឯក។ សមិទ្ធិផលដ៏វិសេសវិសាលនេះ បានប្រមូលផ្តុំវប្បធម៌និងវិទ្យាសាស្ត្រគួរជាទីមោទនៈ ។ ជាប្រាសាទមួយប្លែកអស្ចារ្យ មានភាពសមរម្យទៅតាមទីកន្លែង ការរចនាតុបតែងបានបង្ហាញឱ្យឃើញថា ជាការរចនានៅចន្លោះរវាងការរចនានៅឃ្លាំងនិងនៅបាភួន ។ ចំពោះសិលាចារឹកដែលចារនៅទីនោះទាំងអស់ មានជាភាសាខ្មែរនិងភាសាសំស្ក្រឹត ដែលផ្តល់ប្រយោជន៍ដ៏វិសេសវិសាលបំផុតដល់ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ។...

បើចង់ទៅទស្សនាប្រាសាទព្រះវិហារ គេត្រូវធ្វើដំណើររយៈចម្ងាយ២៩៦គីឡូម៉ែត្រ តាមផ្លូវជាតិលេខ៦និង៦៤ កាត់តាមខេត្តកណ្តាល កំពង់ចាមនិងកំពង់ធំ ។ ហួសពីទីរួមខេត្តកំពង់ធំបន្តិច នោះគេនឹងឃើញផ្លូវបែកពីលេខ៦ទៅ៦៤ ។ ដើម្បីឆាប់ឃើញប្រាសាទ ពេលទៅដល់ទីរួមខេត្តព្រះ

វិហារ គួរទៅសម្រាកក្បែរជើងភ្នំ ព្រោះត្រូវធ្វើដំណើរប្រវែងប្រមាណជាង ១០០ត.មទៀតទើបដល់ ។

ក្រោយពេលស្រស់ស្រូបពេលព្រឹករួច យើងអាចឡើងទៅលើភ្នំដោយថ្មើរជើងឬដោយជិះទោចក្រយានយន្តឬរថយន្ត ។ ពេលឡើងដល់កំពូលភ្នំនោះ យើងនឹងបានជួបគោបុរៈឬទ្វារទី១ ដែលភ្ជាប់ទៅនឹងទីព្រះលានតាំងនៅខាងមុខឆ្ពោះទៅទិសខាងជើង ។ គោបុរៈទី២សំរាប់បើកឱ្យចេញពីទីព្រះលាន ហើយដើរទៅដល់ជណ្តើរនិងតាមជំរាលផ្លូវដ៏វែង ។ តាមផ្លូវជំរាលនោះមាននាគនៅអមទាំងពីរខាង ដែលសាងឡើងជាបង្កាន់ដៃនោះ មិនឱ្យវារលើដីទេគឺមានថ្មទ្រពីក្រោម ។ ទីនេះមានអ្នកលក់អីវ៉ាន់និយាយគួរសមដល់អ្នកដំណើរ អមដោយទេសភាពនិងខ្យល់ត្រជាក់ដ៏គួរឱ្យចាប់ចិត្ត ។ ពេលឡើងទៅជិតដល់ជាន់ទី៣ នៅខាងឆ្វេងដៃ យើងឃើញមានស្រះទឹកដ៏ជ្រៅមួយ ព្រមទាំងមើលឃើញគោបុរៈទី៣ រួចមានជណ្តើរថ្មទៀត ហើយនឹងផ្លូវថ្មល់មួយសំរាប់ឡើងទៅគោបុរៈទី៤ ។ ពីគោបុរៈទី៤ទៅគោបុរៈទី៥សុទ្ធតែមានថ្មល់និងជណ្តើរសំរាប់ឡើងទៅទស្សនាប្រាង្គប្រាសាទដ៏ល្អវិចិត្រ ។

នៅលើភ្នំនៃប្រាសាទព្រះវិហារផ្នែកខាងត្បូង មានដុះថ្មមួយយ៉ាងធំព្រលយចេញហួសពីជញ្ជាំងភ្នំ ។ បច្ចុប្បន្នអ្នកស្រុកហៅថា «ប៉ីយតាឌី» ដែលមានទាក់ទងនឹងរឿងនិទានមួយថា :

កាលពីព្រេងនាយ ប្រទេសខ្មែរមានមេទ័ពម្នាក់ឈ្មោះឌី មានឫទ្ធិអំណាចខ្លាំងពូកែណាស់ ។ លោកតែងច្បាំងឈ្នះប្រទេសជិតខាង ពិសេសប្រទេសសៀមជានិច្ច ។ ពេលច្បាំងម្តងៗ លោកគ្រាន់តែប្រមូលហៅអ្នករាប់អានឱ្យមកជួយច្បាំងតែប៉ុណ្ណោះ ។ ព្រោះលោកចេះមន្តអាគមគួចស្មៅអាចប្រែជាពលទ័ព និងចេះហៅទ័ពខ្មោចឱ្យមកជួយច្បាំងដែរ ។ ហេតុ



ដូច្នេះហើយបានជាលោកច្បាំងតែនៅវេលាយប់ ។

ដោយច្បាំងចេះតែចាញ់ មេទ័ពខាងសៀមបានតាមដានរកចំណុចខ្សោយរបស់លោក ។ គេបានចូលមកស្និទ្ធស្នាលនឹងមិត្តជិតដិតរបស់លោកម្នាក់ ដោយហ៊ានចំណាយទ្រព្យសម្បត្តិយ៉ាងច្រើនដើម្បីទិញចិត្ត ។ ពេលដឹងហេតុគ្រប់សព្វហើយ ខាងសត្រូវបានរកល្បិចច្បាំងជាមួយលោក ដោយពន្យាដល់ពេលថ្ងៃរះ ។ លោកក៏ទទួលបរាជ័យដោយក្តីឈឺចាប់បំផុត ។

ក្រោយបរាជ័យ លោកបានស៊ើបសួរដឹងរឿងថាមានមិត្តជិតស្និទ្ធម្នាក់ក្បត់ចិត្ត លោកក៏ដាច់ចិត្តលោតសម្លាប់ខ្លួនពីព្រលយថ្មមកក្រោម ។ ព្រៃដែលលោកលោតធ្លាក់មកដល់នោះ គេក៏ហៅថាព្រៃតាឌីដែរ ។ បច្ចុប្បន្នអ្នកស្រុកនៅម្តុំនោះ មានជំនឿលើកន្លែងព្រលយនោះណាស់ ។ គេតែងរៀបចំបន់ស្រន់នៅពេលមានទុក្ខ ។

**បញ្ហាវិវាទនៃប្រាសាទព្រះវិហារ :**

ប្រវត្តិសាស្ត្រខ្មែរ តែងបញ្ជាក់ពីការធ្វើអាណានិគមរបស់ប្រទេសបារាំងលើប្រទេសកម្ពុជា ពីឆ្នាំ១៨៦៣ដល់ឆ្នាំ១៩៥៣ ។ ដូច្នេះហើយបានជាមានសន្ធិសញ្ញារវាងប្រទេសបារាំងជាមួយសៀមជាច្រើន មានជាអាទិ :

- **សន្ធិសញ្ញាចុះថ្ងៃទី១៥កក្កដា១៨៦៧**

ប្រទេសសៀមទទួលស្គាល់អាណាព្យាបាលបារាំងលើប្រទេសកម្ពុជា ។ ប្រទេសបារាំងព្រមប្រគល់ខេត្តទាំងពីរ គឺបាត់ដំបងនិងសៀមរាប ឱ្យទៅប្រទេសសៀម ។

- **សន្ធិសញ្ញា ចុះថ្ងៃទី៣តុលា ១៨៩៣**

ប្រទេសសៀមឈប់គួចកាន់ប្រាថ្នា ចង់បានទឹកដីទាំងអស់ដែលស្ថិតលើត្រើយខាងឆ្វេងនៃទន្លេមេគង្គ និងលើកោះទាំងឡាយនៃទន្លេនោះ។ ប្រទេស

សៀមសន្យាមិនដាក់កងកម្លាំងទ័ពអ្វីមួយ នៅក្នុងខេត្តបាត់ដំបងនិងខេត្តសៀមរាបឡើយ ។

~ **សន្ធិសញ្ញា ចុះថ្ងៃទី២៣មិនា ១៩០៧**

ប្រទេសសៀមបានត្រឡប់ប្រគល់ឱ្យមកប្រទេសបារាំងវិញ គឺថាឱ្យមកប្រទេសកម្ពុជានូវខេត្តបាត់ដំបង សៀមរាបនិងស៊ីសុផុន អែលព្រំប្រទល់ដែនដីទៀងទាត់ មានសម្រេចរួចហើយជាស្រេចក្នុង ខ ទាំងឡាយនៃដែនដីទៀងទាត់ ដែលដាក់ជាប់ជាមួយនឹងសន្ធិសញ្ញាស្រាប់។ ចំណែកប្រទេសបារាំងក៏បានប្រគល់ឱ្យសៀមនូវខេត្តដាន់សាយនិងខេត្តត្រាត ព្រមទាំងកោះទាំងអស់ដែលស្ថិតនៅខាងត្បូងជ្រោយឡែនលឹង ដោយរាប់ចូលទាំងកោះកុតផង ។

សន្ធិសញ្ញាបានចែងថា ការកំណត់ព្រំដែនជាក់លាក់នៃដែនដីទាំងឡាយដែលប្រគល់ឱ្យមកនេះ នឹងត្រូវគណៈកម្មការចំរុះជាអ្នកធ្វើក្នុងរយៈពេល៤ខែតាមការសច្ចាប័ននៃសន្ធិសញ្ញា ។...

ក្រោយមកក៏មានអនុសញ្ញាជាច្រើន ដែលចែងឡើងដើម្បីសម្រេចព្រំដែនឱ្យបានទៀងទាត់ ។ ទន្ទឹមនោះក៏មានស្លាបនាផែនទីចំនួនពីរលើកបានបង្ហាញយ៉ាងច្បាស់ថា តំបន់ព្រះវិហារថិតនៅក្នុងដែនដីខ្មែរ ។ ប៉ុន្តែសៀមនៅតែព្យាយាមប្រកាន់អាកប្បកិរិយាកាន់កាប់ប្រាសាទព្រះវិហារ ។ ដូចជារឹងទទឹងរក្សាទាហានឬតម្រួត និងអនុរក្សប្រាសាទរបស់គេឱ្យថិតនៅដែនដីខ្មែរ ។ បញ្ហាដែលត្រឡប់ទៅជាស្មុគស្មាញ គឺព្រោះប្រទេសសៀមមិនព្រមប្រតិបត្តិតាមសន្ធិសញ្ញា ។

ម៉្យាងទៀត មុនប្រទេសកម្ពុជាទទួលបានឯករាជ្យ ស្ថានឯកអគ្គរដ្ឋទូតនៃប្រទេសបារាំងប្រចាំក្រុងបាងកក បានតវ៉ាជាច្រើនលើកច្រើនសាប្រឆាំងនឹងការប្រព្រឹត្តរបស់រាជការថៃ ដូចជាការជញ្ជូនឆ្នាំនិងកម្មករឱ្យមកកាប់ឆ្ការព្រៃនៅប្រាសាទជាដើម ។



ក្រោយបានឯករាជ្យ លិខិតទាំងឡាយអំពីរឿងប្រាសាទព្រះវិហារ បានត្រូវគេផ្ញើប្តូរគ្នាទៅវិញទៅមក រវាងស្ថានឯកអគ្គរាជទូតខ្មែរដែលទើបតាំងនៅថ្មីនាក្រុងបាងកកនិងរដ្ឋាភិបាលប្រទេសថៃ ។ តែលទ្ធផលជាវិជ្ជមានឥតបានកើតមានបន្តិចបន្តួចសោះឡើយ ។ ទោះបីយ៉ាងណាក៏រដ្ឋាភិបាលខ្មែរបានរំលឹករឿងនេះជាញឹកញយឥតល្ហែ ។ តែរដ្ឋាភិបាលថៃនៅតែរឹងទទឹងរក្សាទុកទាហាននៅកន្លែងនោះ ឱ្យជាអ្នកថែរក្សានិងអនុរក្សប្រាសាទដែលថិតនៅក្នុងដែនដីខ្មែរនោះជាអចិន្ត្រៃយ៍ ។ មិនតែប៉ុណ្ណោះ រាជការថៃបានបង្គាប់ឱ្យកម្មករខ្មែរបីនាក់ ដែលរាជការខ្មែរបានជ្រើសរើស យកមកឱ្យនៅថែរក្សាប្រាសាទនោះ ឱ្យឈប់បំពេញមុខងាររបស់ខ្លួន និងឱ្យថយចេញពីទីនោះ ។...

ការប្រព្រឹត្តនៃរាជការថៃនៅតែដដែល ។ ឯរដ្ឋាភិបាលខ្មែរក៏តែងធ្វើសេចក្តីតវ៉ាដូចគ្នានឹងសេចក្តីតវ៉ា ដែលអ្នកតំណាងទាំងឡាយនៃរដ្ឋាភិបាលបារាំងបានផ្ញើជូនទៅរដ្ឋាភិបាលថៃនោះដែរ ។...

គួរឱ្យធុញទ្រាន់ជាពន់ពេក ពីការរៀបរាប់រឿងហេតុទាំងអស់ ដែលបញ្ជាក់ឱ្យឃើញដ៏ពិតប្រាកដនូវឆន្ទៈនៃរាជការប្រទេសថៃ ។

សូមពោលថា ការស្មុគស្មាញមិនអាចដោះស្រាយតាមផ្លូវទូត ឬតាមកិច្ចព្រមព្រៀងសម្រុះសម្រួលបានឡើយ ។ ដូច្នេះរដ្ឋាភិបាលខ្មែរត្រូវដាក់ជូនទៅតុលាការអចិន្ត្រៃយ៍អន្តរជាតិ ។

ទីបំផុតប្រទេសខ្មែរទទួលបានជោគជ័យជាស្ថាពរលើប្រទេសថៃ នាថ្ងៃទី១៥ខែមិថុនាឆ្នាំ១៩៦២ តាមសេចក្តីសម្រេចរបស់តុលាការអន្តរជាតិ នៅទីក្រុងឡាអេនៃប្រទេសហូឡង់ ។